# អរិយធម៌អ៊ីនកា ( Inca civilization)

ប្រវត្តិសាស្ត្រនៃអរិយធម៌អ៊ីនកា គឺជាប្រធានបទមួយដែលមានការជជែកគ្នាយ៉ាងច្រើន ក្នុងចំណោមអ្នកស្រាវជ្រាវមួយចំនួនដូចជា ប្រវត្តិវិទូ, នរវិទូ និងបុរាណវិទូជាដើម ដែលសិក្សាក្នុងតំបន់អាមេរិកខាងត្បូង។ ដោយសារតែវិសាលភាពនៃអរិយធម៌នេះរីកចម្រើនខ្លាំងនៅក្នុងតំបន់អាមេរិកខាងត្បូង ជាពិសេសស្ថានីយបុរាណជាច្រើនដែលបន្សល់នៅតាមបណ្ដាប្រទេសក្នុងតំបន់អាមេរិកខាងត្បូង។ អរិយធម៌ អ៊ីនកា (Inca, Inka) ឬហៅម្យ៉ាងទៀតថា តាហួនទីនស៊ូ (Tahuantinsuyu) ដែលបច្ចុប្បន្នស្ថិតនៅខាងត្បូងនៃប្រទេសប៉េរូ ហើយអរិយធម៌នេះ គឺជាអរិយធម៌ដ៏សំខាន់ និងរុងរឿងជាងគេនៅក្នុងប្រវត្តិសាស្ត្រនៃប្រទេសប៉េរូ និងក៏សំខាន់នៅក្នុងតំបន់អាមរិកដែរ បើប្រៀបធៀបជាមួយនឹងអរិយធម៌ធំផ្សេងៗទៀតក្នុងតំបន់ រួមមានអតិច ម៉ាយ៉ា ជាដើម។ អរិយធម៌នេះកកើតឡើងដំបូងនៅក្នុងតំបន់អង់ឌៀន នៅអំឡុងស.វ.ទី១២ នៃគ.ស. និងនៅអំឡុងស.វ.ទី១៥ អរិយធម៌នេះបានក្លាយជាអាណាចក្រអ៊ីនកាមួយ ដែលមានផ្ទៃដីយ៉ាងធំធេងលាតសន្ធឹងចាប់ពីខាងជើងប្រទេស អេក្វាទ័រ ឈីលី រហូតដល់ប្រទេសប៉េរូ ( រូបលេខ១)។[១]

តាមរយៈសំណល់វត្ថុសិល្បៈ និងសំណង់ស្ថាបត្យកម្មផ្សេងៗនៅក្នុងតំបន់ប្រាសាទម៉ាជូ ភីចឈូ (Machu Picchu) និងតំបន់គុសកូ (Cuzco ) ត្រូវបានអ្នកស្រាវជ្រាវដឹងថា ទីតាំងទាំងពីរនេះ គឺជាអតីតទីក្រុងដ៏សំខាន់នៅក្នុងអរិយធម៌អ៊ីនកា (រូបលេខ២-៣)។ ទីក្រុងម៉ាជូភីចឈូ គឺសង់នៅលើតំបន់ជ្រលងភ្នំអង់ឌៀនដ៏ខ្ពស់ដែលមានកម្ពស់ប្រមាណ ២៤៣០ម៉ែត្រពីកំពស់នីវ៉ូទឹកសមុទ្រ។[២] ទីក្រុងទាំងនេះកសាងនៅពាក់កណ្ដាលស.វ.ទី១៥ និងសំណង់សង់ជារាងថ្នាក់ៗតាមជំរាលភ្នំស្របទៅនឹងទីតាំងភូមិសាស្ត្រនៅតំបន់ទីនោះ ព្រមទាំងបានដាក់បញ្ចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោកក្នុងឆ្នាំ១៩៨៣។[៣] ទីក្រុងនេះត្រូវបានបោះបង់ចោលនៅចុងស.វ.ទី១៦ និងរកឃើញវិញនៅស.វ.ទី២០ ដោយអ្នកបុរាណវិទូជនជាតិអាមេរិក

---

[១] https://www.history.com/topics/south-america/inca

[២] ibid

[៣] https://whc.unesco.org/en/list/274/

អត្ថបទដោយ៖ អេង តុលា

ម្នាក់ឈ្មោះ Hiram Bingham (រូបលេខ៤)។[៤] ក្រោយមកទៀត ទីក្រុង គុសកូ (Cuzco) គឺជាទីក្រុងចាស់នៃអរិយធម៌អ៊ីនកា ដែលបង្កើតឡើងនៅចុងស.វ.ទី១៥ បន្ទាប់ពីទីក្រុងម៉ាជូ ភីចឈូ។ ទីក្រុង Cuzco គឺជាទីក្រុងស្នូលនៃអរិយធម៌អ៊ីនកា ឬ Tawantinsuyu ដែលជាទីក្រុងផ្នែកនយោបាយ សាសនា និងរដ្ឋបាលរវាងចុងសតវត្សទី ១៥ និងទី១៦ (រូបលេខ៥)។[៥]

ដោយឡែកសំណង់ស្ថាបត្យកម្មនៃអរិយធម៌នេះ គឺមានភាពអស្ចារ្យនៃស្នាដៃមនុស្សសម័យបុរាណ ជាអាទិ៍សំណង់ក្រុងបុរាណ ម៉ាជូ ភីចឈូ ។ បើប្រៀបធៀបទៅនឹងសំណង់ក្រុងនៃអរិយធម៌ផ្សេងៗ ដូចធ្លាប់បានបង្ហាញកន្លងមកក្នុងអត្ថបទសំណេររបស់ខ្ញុំដែលបានផ្សព្វផ្សាយក្នុងប្រព័ន្ធវេបសាយ AMS ***អរិយធម៌ខ្មែរ*** ឃើញថាសំណង់នៃក្រុងនេះ គឺមានបច្ចេកទេសខ្ពស់ និងមានស្នាដៃប៉ិនប្រសប់ខាងស្ថាបត្យកម្ម ដ្បិតទីក្រុងនេះសាងសង់នៅលើភ្នំដែលមានកំពស់ខ្ពស់។ ចំពោះការរៀបចំក្រុងនៃអរិយធម៌នេះ គឺជាការរៀបចំជាបណ្តុំនៃសំណង់ ដែលសម្រាប់ការគោរពដល់ព្រះក្នុងអរិយធម៌អ៊ីនកាបុរាណ។ លើសពីនេះតាមរយៈសំណង់ សិល្បៈ ស្ថាបត្យកម្មអ្នកស្រាវជ្រាវបានដឹងថា ប្រជាជអ៊ីនកាមានចំណេះដឹងខាងផ្នែកគណិតវិទ្យា តារាសាស្រ្ត ប្រតិទិន និងការរៀបចំក្រុង។ មនុស្សនៅក្នុងអរិយធម៌នេះគោរពប្រតិបត្តិលើអទិទេព Inti ដែលជាអទិទេពនៃព្រះអាទិត្យ។[៦]

ប្រហែលនៅចុងស.វ.ទី១៥ បណ្តាទីក្រុងនៃអរិយធម៌អ៊ីនកាត្រូវបានបោះបង់ចោល និងនៅដើមស.វ.ទី១៦ អាណាចក្រនេះត្រូវបានដួលរលំទាំងស្រុង ដោយការវាយលុកលុយពីសំណាកជនជាតិអេស្ប៉ាញដែលបានចូលមកដល់ក្នុងទ្វីបអាមេរិក និងបណ្តាលមកពីការប្រែប្រួលអាកាសធាតុក្នុងតំបន់។[៧]

យោងតាមការសិក្សាតាមសំណង់ស្ថាបត្យកម្ម សិល្បៈដែលបានបន្សល់ពីអរិយធម៌អ៊ីនកា អ្នកស្រាវជ្រាវបានបង្ហាញថា អរិយធម៌នៃអាណាចក្រអ៊ីនកាមានឥទ្ធិពលខ្លាំងក្លា រុងរឿង

---

[៤] https://www.history.com/this-day-in-history/machu-picchu-discovered#:~:text=On%20July%2024%2C%201911%2C%20American,the%20world's%20top%20tourist%20destinations.

[៥] https://whc.unesco.org/en/list/273

[៦] https://www.britannica.com/topic/Inti-Inca-Sun-god

[៧] www.history.com

ជាងគេនៅតំបន់អាមេរិកខាងត្បូង និងជាអរិយធម៌ចុងក្រោយគេបង្អស់នៅក្នុងប្រទេសប៉េរូ ដែលជាប្រទេសសំបូរទៅដោយ អរិយធម៌ និងវប្បធម៌បុរាណ។




រូបលេខ១៖ ផែនទីនៃវិសាលភាពអាណាចក្រអ៊ីនកាបុរាណ

ប្រភព៖ https://www.classroomclipart.com

អត្ថបទដោយ៖ អេង តុលា





រូបលេខ ២-៣៖ ទីក្រុង Machu Picchu និង Cuzco

ប្រភព៖ Internet






រូបលេខ ៣-៤ ៖ ប្លង់នៃ ទីក្រុង Machu Picchu និង Cuzco

របភព៖ Internet









រូបលេខ ៥-៨ ៖ សិល្បៈនៃអរិយធម៌អ៊ីនកា

ប្រភព៖ Internet

# ឯកសារយោង

https://www.history.com/topics/south-america/inca

https://whc.unesco.org/en/list/274/

https://www.history.com/this-day-in-history/machu-picchu-discovered#:~:text=On%20July%2024%2C%201911%2C%20American,the%20world's%20top%20tourist%20destinations.

https://whc.unesco.org/en/list/273

https://www.britannica.com/topic/Inti-Inca-Sun-god

www.history.com

KHMER CIVILIZATION